ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# អាជ្ញាធរអគ្គិសនីកម្ពុជា

# នីតិវិធី

## សម្រាប់ការតាមដានទិន្នន័យ ការដាក់ពាក្យស្នើសុំ
## ការពិនិត្យមើលឡើងវិញ និងការកំណត់បញ្ជីថ្លៃលក់អគ្គិសនី

ក្នុងក្របខណ្ឌច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា

អនុម័តដោយសម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជាលើកទី ១១៣
នៅថ្ងៃទី ២៦ ខែតុលា ឆ្នាំ ២០០៧

# សេចក្តីសម្រេច

## ស្តីពីការតាមដានទិន្នន័យ ការដាក់ពាក្យស្នើសុំ ការពិនិត្យមើលឡើងវិញ និងការកំណត់បញ្ជីថ្លៃលក់អគ្គិសនី

## អាជ្ញាធរអគ្គិសនីកម្ពុជា

-អនុវត្តតាមច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ ២០០១

-អនុវត្តតាមព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកត/១១០៤/០២២ ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង **ឯកឧត្តម ទី នរិទ្ធ** ជាប្រធាននៃអាជ្ញាធរអគ្គិសនីកម្ពុជា

-បានឃើញអនុក្រឹត្យលេខ៥៤.អនក្រ.បក ចុះថ្ងៃទី ០៨ ខែមេសា ឆ្នាំ ២០០៥ ស្តីពីគោលការណ៍វាយតម្លៃភាពត្រឹមត្រូវនៃចំណាយក្នុងអាជីវកម្មអគ្គិសនី

-យោងតាមការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អ្នកកាន់អាជ្ញាប័ណ្ណ និងសាធារណជន ដែលធ្វើឡើងចាប់ពីថ្ងៃ ២៥ ខែឧសភា ឆ្នាំ ២០០៧ ដល់ថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ ២០០៧

-បានឃើញបទប្បញ្ញត្តិស្តីពីគោលការណ៍ទូទៅសម្រាប់កំណត់បញ្ជីថ្លៃលក់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា

-យោងតាមការអនុម័តរបស់សម័យប្រជុំលើកទី ១១៣ របស់អាជ្ញាធរអគ្គិសនីកម្ពុជា នៅថ្ងៃទី ២៦ ខែតុលា ឆ្នាំ ២០០៧

## សម្រេច

**ប្រការ ១.-**

ចេញនូវនីតិវិធីមួយមានឈ្មោះថា “នីតិវិធីសម្រាប់ការតាមដានទិន្នន័យ ការដាក់ពាក្យស្នើសុំ ការពិនិត្យមើលឡើងវិញ និងការកំណត់បញ្ជីថ្លៃលក់អគ្គិសនី” ក្នុងក្របខ័ណ្ឌច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់គ្រប់គ្រងដំណើរការនៃការទទួលនិងការតាមដានទិន្នន័យរបស់អ្នកកាន់អាជ្ញាប័ណ្ណ ព្រមទាំងការពិនិត្យមើលឡើងវិញនិងការកំណត់បញ្ជីថ្លៃលក់ អគ្គិសនីរបស់អ្នកកាន់អាជ្ញាប័ណ្ណ ដើម្បីធានានូវតុល្យភាពមួយដ៏យុត្តិធម៌និងសមធម៌ រវាងផលប្រយោជន៍របស់អ្នកផ្គត់ផ្គង់ និងផលប្រយោជន៍របស់អ្នក ប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ២.-**

នីតិវិធីនេះមានខ្លឹមសារទាំងស្រុងដូចអត្ថបទដែលភ្ជាប់មកជាមួយ ។

**ប្រការ ៣.-**

នីតិវិធីនេះមានប្រសិទ្ធភាពអនុវត្តចំពោះរាល់អ្នកកាន់អាជ្ញាប័ណ្ណចែកចាយ អ្នកកាន់អាជ្ញាប័ណ្ណលក់រាយ អ្នកកាន់អាជ្ញាប័ណ្ណរួម (ដែលមានការធ្វើសេវាកម្មចែកចាយ ឬការធ្វើសេវាកម្មលក់រាយ) និងចំពោះអ្នកប្រើប្រាស់ ទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ទាក់ទងនឹងការផ្គត់ផ្គង់ ការទទួល និងការប្រើប្រាស់អគ្គិសនី ។

**ប្រការ ៤.-**

នីតិវិធីនេះត្រូវចូលជាធរមានសម្រាប់អនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ រហូតដល់មានការសម្រេចជាថ្មី ។ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកែសម្រួលនិងចេញនីតិវិធីនេះឡើងវិញ នៅគ្រប់ពេល ។

**ប្រការ ៥.-**

លេខាធិការដ្ឋាននៃអាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវផ្សព្វផ្សាយនីតិវិធីនេះជា សាធារណៈ ។

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

# តារាងមាតិកា


**នីតិវិធី "ក" : នីតិវិធីសម្រាប់ការផ្តល់ទិន្នន័យប្រចាំឆ្នាំដោយអ្នកកាន់អាជ្ញាប័ណ្ណ និងការតាមដានទិន្នន័យទាំងនោះ**

១.១- គោលបំណងរបស់នីតិវិធី "ក"

១.២- ការកំណត់អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនធំ និងអ្នកកាន់ អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនតូចសម្រាប់ការកំណត់បញ្ជីថ្លៃលក់

១.៣- ការផ្តល់ទិន្នន័យប្រចាំឆ្នាំដោយអ្នកកាន់អាជ្ញាប័ណ្ណ និងសកម្មភាពរបស់អាជ្ញាធរអគ្គិសនីកម្ពុជា

១.៤- សេចក្តីសម្រេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជាក្នុងការពិនិត្យបញ្ជីថ្លៃ លក់អគ្គិសនីឡើងវិញ

១.៥- ការពិនិត្យទិន្នន័យ និងភាពចាំបាច់ក្នុងការកែសម្រួលបញ្ជីថ្លៃលក់ អគ្គិសនី

**នីតិវិធី "ខ" : នីតិវិធីសម្រាប់ការដាក់ពាក្យស្នើសុំកំណត់បញ្ជីថ្លៃលក់អគ្គិសនី**

២.១- គោលបំណងរបស់នីតិវិធី "ខ"

២.២- ការដាក់ពាក្យស្នើសុំកំណត់បញ្ជីថ្លៃលក់អគ្គិសនីដោយអ្នកកាន់-អាជ្ញាប័ណ្ណ

២.៣- ឯកសារពិនិត្យបញ្ជីថ្លៃលក់អគ្គិសនីឡើងវិញ

២.៤- ការវាយតម្លៃពាក្យស្នើសុំកំណត់ថ្លៃលក់អគ្គិសនី/ឯកសារពិនិត្យ បញ្ជីថ្លៃលក់អគ្គិសនីឡើងវិញ ដោយលេខាធិការដ្ឋានអាជ្ញាធរ អគ្គិសនីកម្ពុជា

២.៥- ថ្ងៃទទួលពាក្យស្នើសុំកំណត់បញ្ជីថ្លៃលក់អគ្គិសនី

**នីតិវិធី "គ" : នីតិវិធីសម្រាប់ការពិនិត្យនិងការកំណត់បញ្ជីថ្លៃ លក់អគ្គិសនីរបស់អ្នកកាន់អាជ្ញាប័ណ្ណ**

៣.១- គោលបំណងរបស់នីតិវិធី "គ"

៣.២- ការផ្សព្វផ្សាយអំពីការដាក់ពាក្យស្នើសុំនិងឯកសារពិនិត្យថ្លៃបញ្ជីលក់អគ្គិសនីឡើងវិញ

៣.៣- សិទ្ធិរបស់សាធារណជនក្នុងការផ្តល់មតិយោបល់លើពាក្យស្នើ សុំកំណត់បញ្ជីថ្លៃលក់អគ្គិសនី/ឯកសារពិនិត្យបញ្ជីថ្លៃលក់អគ្គិសនី ឡើងវិញ- ការពិគ្រោះយោបល់សាធារណៈ

៣.៤- ឯកសារដែលត្រូវមានសម្រាប់សាធារណជនពិនិត្យ

៣.៥- ការវាយតម្លៃលើការផ្តល់យោបល់របស់សាធារណជន និងការទទួលពត៌មានបន្ថែម

៣.៦- ការវាយតម្លៃលើការស្នើសុំកំណត់បញ្ជីថ្លៃលក់ ឬឯកសារ ពិនិត្យបញ្ជីថ្លៃលក់ឡើងវិញ

៣.៧- ការបើកសវនាការពិគ្រោះយោបល់របស់អាជ្ញាធរអគ្គិសនីកម្ពុជា

៣.៨- សម័យប្រជុំពិគ្រោះយោបល់របស់អាជ្ញាធរអគ្គិសនីកម្ពុជា

៣.៩- សេចក្តីសម្រេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជា

៣.១០- ពត៌មានអំពីបញ្ជីថ្លៃលក់

**ឧបសម្ព័ន្ធទី១ :** ការផ្តល់ទិន្នន័យប្រចាំឆ្នាំរបស់អ្នកកាន់អាជ្ញាប័ណ្ណធ្វើ សេវាកម្មធុនធំ

**ឧបសម្ព័ន្ធទី២ :** ការស្នើសុំកែសម្រួលបញ្ជីថ្លៃលក់អគ្គិសនីរបស់ អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនធំ

**ឧបសម្ព័ន្ធទី៣ :** ការផ្តល់ទិន្នន័យប្រចាំឆ្នាំរបស់អ្នកកាន់អាជ្ញាប័ណ្ណ ធ្វើសេវាកម្មធុនតូច

**ឧបសម្ព័ន្ធទី៤ :** ការស្នើសុំកែសម្រួលបញ្ជីថ្លៃលក់អគ្គិសនីរបស់ អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនតូច

# ការរៀបចំឯកសារ

នីតិវិធីនេះបានត្រូវបែងចែកជានីតិវិធីដោយឡែកពីគ្នាចំនួនបី។ នីតិវិធីដោយ ឡែកនីមួយៗ មានចំណងជើងមួយដែលកំណត់ថាជាអត្តសញ្ញាណនៃនីតិវិធីដោយឡែកនោះ។ (ឧទាហរណ៍: **នីតិវិធី "ក"** មានន័យថា នីតិវិធី សម្រាប់ការផ្តល់ទិន្នន័យប្រចាំឆ្នាំរបស់អ្នកកាន់អាជ្ញាប័ណ្ណ និងការតាមដានទិន្នន័យ) ។

"មាត្រានីមួយៗ មានចំណងជើងមួយ និងមានវាក្យខ័ណ្ឌនៅក្នុងមាត្រានោះ ដែលមានសម្រាប់យោង (ឧទាហរណ៍ មាត្រា១.៧ មានន័យថាជាបញ្ញត្តិកំណត់ក្នុងមាត្រាដែលមានលេខ៧ នៅខាងមុខមាត្រានោះ) ។

ក្នុងនីតិវិធីនេះ ប្រសិនបើពុំមានការបញ្ជាក់ខ្លឹមសារផ្សេងទេ ពាក្យខាង ក្រោមនេះ ត្រូវមានន័យ ដូចខាងក្រោម:

**"អ.អ.ក"** មានន័យថាអាជ្ញាធរអគ្គិសនីកម្ពុជាដែលបង្កើតឡើងដោយច្បាប់ ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា

**"អ.ក"** មានន័យថាក្រុមហ៊ុនអគ្គិសនីកម្ពុជារួមទាំងសាខានានានៅកម្ពុជា

**"ច្បាប់"** មានន័យថាច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០១

**"អាជ្ញាប័ណ្ណ"** មានន័យថាអាជ្ញាប័ណ្ណណាមួយដែលចេញដោយអាជ្ញាធរ អគ្គិសនីកម្ពុជា អនុលោមតាមច្បាប់ ដែលបទប្បញ្ញត្តិនេះត្រូវអនុវត្ត។

**"អ្នកកាន់អាជ្ញាប័ណ្ណ"** មានន័យថាអ្នកកាន់អាជ្ញាប័ណ្ណណាមួយដែល បទប្បញ្ញត្តិនេះត្រូវអនុវត្ត។

**"នីតិវិធី"** មានន័យថានីតិវិធីសម្រាប់ការតាមដានទិន្នន័យ ការដាក់ពាក្យ ស្នើសុំ ការពិនិត្យមើលឡើងវិញ និងការកំណត់បញ្ជីថ្លៃលក់អគ្គិសនី

**"បទប្បញ្ញត្តិ"** មានន័យថាបទប្បញ្ញត្តិស្តីពីគោលការណ៍ទូទៅសម្រាប់កំណត់ បញ្ជីថ្លៃលក់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា

**"អនុក្រឹត្យ"** មានន័យថាអនុក្រឹត្យស្តីពីគោលការណ៍វាយតម្លៃភាពត្រឹមត្រូវ នៃចំណាយក្នុងអាជីវកម្មអគ្គិសនី អនុលោមតាមច្បាប់ស្តីពីអគ្គិសនី។

# នីតិវិធី "ក"

## នីតិវិធីសម្រាប់ការផ្តល់ទិន្នន័យប្រចាំឆ្នាំដោយអ្នកកាន់អាជ្ញាប័ណ្ណនិងការតាមដានទិន្នន័យទាំងនោះ

### ១.១. គោលបំណងរបស់នីតិវិធី "ក"

នីតិវិធី"ក" គឺទាក់ទងនឹងតួនាទីរបស់អាជ្ញាធរអគ្គិសនីកម្ពុជាក្នុងការតាមដាន ស្ថានភាពបញ្ជីថ្លៃលក់អគ្គិសនីរបស់អ្នកកាន់អាជ្ញាប័ណ្ណនីមួយៗ។ នីតិវិធីនេះតម្រូវឱ្យអ្នកកាន់អាជ្ញាប័ណ្ណ ផ្តល់ឱ្យអាជ្ញាធរនូវទិន្នន័យប្រចាំឆ្នាំ និងពត៌មាន ផ្សេងទៀតទាក់ទងនឹងបញ្ជីថ្លៃលក់អគ្គិសនីរបស់ខ្លួន ហើយអាជ្ញាធរពិនិត្យទិន្នន័យទាំងនោះ និងសម្រេចថា តើត្រូវការទិន្នន័យឬពត៌មានបន្ថែម ទៀតឬទេ។ ប្រសិនបើអាជ្ញាធរកំណត់ថាត្រូវការបន្ថែមទៀត នោះអាជ្ញាធរនឹងស្នើសុំផ្តល់ពត៌មានបន្ថែម រួចបន្តទៅនីតិវិធី "គ" ។

### ១.២.ការកំណត់អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនធំ និងអ្នកកាន់ អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនតូច សម្រាប់ការកំណត់បញ្ជីថ្លៃលក់

អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវជូនដំណឹងអំពីបញ្ជីអ្នកកាន់អាជ្ញាប័ណ្ណ ដែលកំណត់ បែងចែកអ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនធំ និងអ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនតូច។ អាជ្ញាធរអាចជូនដំណឹងអំពីការផ្លាស់ប្តូរការកំណត់ របស់អ្នកកាន់អាជ្ញាប័ណ្ណណាមួយ ឬជូនដំណឹងអំពីបញ្ជីអ្នកកាន់អាជ្ញាប័ណ្ណ ថ្មីនៅពេលណាមួយ ។

### ១.៣.ការផ្តល់ទិន្នន័យប្រចាំឆ្នាំដោយអ្នកកាន់អាជ្ញាប័ណ្ណ និង សកម្មភាពរបស់អាជ្ញាធរអគ្គិសនីកម្ពុជា

(i) ដើម្បីអាចឱ្យអាជ្ញាធរអគ្គិសនីកម្ពុជាមានទិន្នន័យថ្មីៗសម្រាប់ធ្វើ ការកំណត់បញ្ជីថ្លៃលក់ អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនធំទាំងអស់ត្រូវផ្តល់ឱ្យអាជ្ញាធរមិនឱ្យហួសថ្ងៃទី៣១ ខែមីនា ជារៀងរាល់ ឆ្នាំនូវទិន្នន័យ និងពត៌មានផ្សេងទៀតទាក់ទងនឹងថ្លៃលក់អគ្គិសនី របស់ខ្លួនដែលមាន

កំណត់ក្នុង ឧបសម្ព័ន្ធទី១ ។ ទិន្នន័យនេះ ត្រូវផ្តល់ឱ្យអាជ្ញាធរជាឯកសារផ្នែកទន់ (soft copy) ក្នុងកម្មវិធី MS Excel និងឯកសារផ្នែករឹង (hard copy) ចំនួន ១ច្បាប់ ។

(ii) អ្នកកាន់អាជ្ញាប័ណ្ណធុនតូចទាំងអស់ ត្រូវផ្តល់ឱ្យអាជ្ញាធរអគ្គិសនី កម្ពុជា មិនឱ្យហួសថ្ងៃទី៣១ ខែមីនា ជារៀងរាល់ឆ្នាំនូវទិន្នន័យ និងពត៌មានផ្សេងៗតាមតារាងកំណត់ក្នុង ឧបសម្ព័ន្ធទី៣ ។ ទិន្នន័យនេះត្រូវផ្តល់ឱ្យអាជ្ញាធរជាឯកសារផ្នែករឹង (hard copy) ចំនួន០១ច្បាប់ ។ ប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណមាន លទ្ធភាព អាជ្ញាធរចង់បានការផ្តល់ទិន្នន័យជាឯកសារផ្នែកទន់ (soft copy) ក្នុងកម្មវិធី MS Excel ផងដែរ ។

(iii) អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវតាមដាននិងពិនិត្យទិន្នន័យប្រចាំឆ្នាំ ដែលទទួលបានពីអ្នកកាន់អាជ្ញាប័ណ្ណ ដើម្បីវាយតម្លៃភាពត្រឹមត្រូវ ថាតើការដាក់ពាក្យស្នើសុំនោះអនុលោមតាមល័ក្ខខ័ណ្ឌរបស់ នីតិវិធីនេះឬទេ ។ ប្រសិនបើមិនត្រឹមត្រូវទេ អាជ្ញាធរនឹងជូនដំណឹង ដល់អ្នកកាន់អាជ្ញាប័ណ្ណអំពីពត៌មានដែលខ្វះ ឬពត៌មានមិនពេញ លេញដែលត្រូវផ្តល់ឱ្យអាជ្ញាធរក្នុងរយៈពេលកំណត់មួយ ។

## ១.៤. សេចក្តីសម្រេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជាក្នុងការពិនិត្យ បញ្ជីថ្លៃលក់ឡើងវិញ

(i) អាជ្ញាធរអគ្គិសនីកម្ពុជា អាចពិនិត្យបញ្ជីថ្លៃលក់អគ្គិសនីឡើងវិញ ដោយផ្អែកលើការផ្តល់ទិន្នន័យប្រចាំឆ្នាំ ពត៌មានដែលផ្តល់ ដោយអ្នកប្រើប្រាស់ ឬភាគីទីបី ឬផ្អែកតាមហេតុផលណាមួយ ផ្សេងទៀត ដើម្បីកំណត់ថាបញ្ជីថ្លៃលក់អគ្គិសនីរបស់អ្នកកាន់ អាជ្ញាប័ណ្ណណាមួយត្រូវតែពិនិត្យមើលឡើងវិញ ។

(ii) នៅពេលដែលអាជ្ញាធរអគ្គិសនីកម្ពុជាកំណត់ថា បញ្ជីថ្លៃលក់ អគ្គិសនីរបស់អ្នកកាន់អាជ្ញាប័ណ្ណណាមួយត្រូវតែពិនិត្យមើលឡើងវិញ អាជ្ញាធរត្រូវជូនដំណឹងដល់អ្នកកាន់អាជ្ញាប័ណ្ណនោះអំពីការ ពិនិត្យឡើងវិញនេះ និងសុំឱ្យអ្នកកាន់អាជ្ញាប័ណ្ណផ្តល់ទិន្នន័យ ចាំបាច់ ដូចមានក្នុង ឧបសម្ព័ន្ធទី២សម្រាប់អ្នកកាន់អាជ្ញាប័ណ្ណ ធ្វើសេវាកម្មធុនធំ និងដូចមានក្នុង ឧបសម្ព័ន្ធទី៤សម្រាប់ អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនតូច ក្នុងរយៈពេល ៣០ (សាមសិប)ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹង ហើយអ្នកកាន់អាជ្ញាប័ណ្ណ មានកាតព្វកិច្ចផ្តល់ពត៌មានទាំងនេះ តាមពេលវេលាកំណត់ ។ ប្រសិនបើ អាជ្ញាធរអគ្គិសនីកម្ពុជាយល់ថាចាំបាច់ អាជ្ញាធរអាច បញ្ជូនមន្ត្រីរបស់ខ្លួនចុះទៅពិនិត្យ ផ្ទៀងផ្ទាត់ទិន្នន័យពាក់ព័ន្ធនឹង ប្រតិបត្តិការរបស់អ្នកកាន់អាជ្ញាប័ណ្ណ ហើយអ្នកកាន់អាជ្ញាប័ណ្ណ មានកាតព្វកិច្ចសហការជាមួយមន្ត្រីនោះឱ្យបានល្អប្រសើរ ។

## ១.៥. ការពិនិត្យទិន្នន័យ និងភាពចាំបាច់ក្នុងការកែសម្រួលបញ្ជី ថ្លៃលក់អគ្គិសនី

(i) អាជ្ញាធរអគ្គិសនីកម្ពុជានឹងពិនិត្យមើលទិន្នន័យដែលមាន និង ពិចារណាមើលថាតើត្រូវបន្តចូលដល់ដំណើរការនៃការពិនិត្យបញ្ជីថ្លៃលក់អគ្គិសនី ឡើងវិញឬទេ ។ នៅពេលណាដែលអាជ្ញាធរយល់ថានេះជាការចាំបាច់ អាជ្ញាធរនឹងដំណើរការការពិនិត្យ បញ្ជីថ្លៃលក់អគ្គិសនីឡើងវិញ អនុលោមទៅតាមល័ក្ខខ័ណ្ឌនៃនីតិវិធី“គ” ហើយអាជ្ញាធរត្រូវជូនដំណឹងដល់អ្នកកាន់អាជ្ញាប័ណ្ណ អំពីការសម្រេចពិនិត្យបញ្ជីថ្លៃលក់អគ្គិសនី ឡើងវិញនោះ ។

(ii) នៅពេលអាជ្ញាធរសម្រេចថាចាំបាច់ត្រូវដំណើរការការពិនិត្យ បញ្ជីថ្លៃលក់របស់អ្នកកាន់អាជ្ញាប័ណ្ណណាមួយឡើងវិញ អាជ្ញាធរត្រូវផ្តល់ឱ្យ អ្នកកាន់អាជ្ញាប័ណ្ណនោះនូវរយៈពេល១៤ (ដប់បួន)ថ្ងៃ បន្ថែមទៀតគិតចាប់ពីថ្ងៃជូនដំណឹងចែងក្នុងវាក្យខ័ណ្ឌទី១នៃមាត្រា១.៥ ដើម្បីឱ្យ អ្នកកាន់អាជ្ញាប័ណ្ណនោះផ្តល់ពត៌មានណាមួយ បន្ថែមទៀតដែលខ្លួនចង់ផ្តល់ ។

## នីតិវិធី "ខ"

## នីតិវិធីសម្រាប់ការដាក់ពាក្យស្នើសុំកំណត់បញ្ជីថ្លៃលក់អគ្គិសនី

### ២.១- គោលបំណងរបស់នីតិវិធី "ខ"

នីតិវិធី "ខ" ទាក់ទងនិងសិទ្ធិរបស់អ្នកកាន់អាជ្ញាប័ណ្ណក្នុងការដាក់ពាក្យ ស្នើសុំពិនិត្យបញ្ជីថ្លៃលក់អគ្គិសនី។ សិទ្ធិទាំងនោះរួមមាន:

(i) អ្នកកាន់អាជ្ញាប័ណ្ណមានបំណងដាក់ពាក្យស្នើសុំកែសម្រួលបញ្ជីថ្លៃលក់របស់ខ្លួនឡើងវិញ ឬ

(ii) អ្នកស្នើសុំអាជ្ញាប័ណ្ណថ្មីចង់ដាក់ពាក្យស្នើសុំអនុម័តបញ្ជីថ្លៃលក់ អគ្គិសនី។

ក្នុងករណីទាំងពីរ គឺត្រូវអនុវត្តតាមនីតិវិធីនេះ។

នីតិវិធី "ខ"នេះ កំណត់អំពីពត៌មានអ្វីខ្លះដែលត្រូវផ្តល់ឱ្យអាជ្ញាធរ និងការ

ពិនិត្យមើលរបស់អាជ្ញាធរថាតើការផ្តល់នោះមានភាពត្រឹមត្រូវនិងពេញលេញឬទេ។ នៅពេលដែលពាក្យស្នើសុំនោះមានលក្ខណៈត្រឹមត្រូវនិងទទួលយកបានដោយអាជ្ញាធរ ត្រូវបន្តទៅនីតិវិធី "គ" ។

### ២.២- ការដាក់ពាក្យស្នើសុំកំណត់បញ្ជីថ្លៃលក់អគ្គិសនីដោយ អ្នកកាន់អាជ្ញាប័ណ្ណ

(i) អ្នកកាន់អាជ្ញាប័ណ្ណត្រូវដាក់ពាក្យស្នើសុំកំណត់បញ្ជីថ្លៃលក់មក អាជ្ញាធរអគ្គិសនីកម្ពុជាយ៉ាងតិច០៤(បួន)ខែ មុនថ្ងៃខ្លួនចង់អនុវត្តបញ្ជីថ្លៃលក់អគ្គិសនីដែលស្នើសុំនេះ។

(ii) អ្នកកាន់អាជ្ញាប័ណ្ណត្រូវដាក់ពាក្យស្នើសុំមកលេខាធិការដ្ឋាន អាជ្ញាធរអគ្គិសនីកម្ពុជា ដោយត្រូវភ្ជាប់ជាមួយនូវពត៌មានទាំង ឡាយដូចខាងក្រោម:

(ក) បញ្ជីថ្លៃលក់ដែលកំពុងអនុវត្តរួមជាមួយនិងល័ក្ខខ័ណ្ឌ របស់វាទាំងអស់ដែលត្រូវអនុវត្ត ប្រសិនបើមាន

(ខ) បញ្ជីថ្លៃលក់ថ្មីរួមជាមួយនិងល័ក្ខខ័ណ្ឌពាក់ព័ន្ធទាំងអស់ ដែលខ្លួនស្នើសុំ

(គ) គណនីដែលបានធ្វើសវនកម្មរួចសម្រាប់ឆ្នាំការិយបរិច្ឆេទ ចុងក្រោយបំផុត។ ប្រសិនបើគណនីសម្រាប់ឆ្នាំការិយបរិច្ឆេទចុងក្រោយបំផុត មិនទាន់បានធ្វើសវនកម្មរួច ដោយសារតែការធ្វើសវនកម្មមិនទាន់ចប់ ពេលនោះ អាចផ្តល់គណនីដែលមិនទាន់ធ្វើសវនកម្មសម្រាប់ឆ្នាំ ការិយបរិច្ឆេទមុននេះបាន រួមជាមួយនិងគណនីដែលបានធ្វើសវនកម្មរួចសម្រាប់ឆ្នាំការិយបរិច្ឆេទមុនបន្ទាប់ដែល មាន។ ប្រសិនបើ អ្នកកាន់អាជ្ញាប័ណ្ណមិនអាចមានគណនីដែលបានធ្វើសវនកម្ម ដោយសារមូលហេតុ ណាមួយ ដែលយល់ព្រមដោយអាជ្ញាធរអគ្គិសនីកម្ពុជា ពេលនោះ អ្នកកាន់អាជ្ញាប័ណ្ណត្រូវផ្តល់ឱ្យអាជ្ញាធរនូវ គណនី ដើម្បីឱ្យអាជ្ញាធរត្រួតពិនិត្យ អនុលោមតាម ល័ក្ខខ័ណ្ឌអាជ្ញាប័ណ្ណ។ ក្នុងករណីនេះជំនួសឱ្យគណនី ដែលបានធ្វើសវនកម្មរួច អ្នកកាន់អាជ្ញាប័ណ្ណអាចផ្តល់នូវគណនីដែលត្រូវបានត្រួតពិនិត្យរួចដោយអាជ្ញាធរបាន។

(ឃ) របាយការណ៍អំពីការឧបត្ថម្ភធនណាមួយដែលខ្លួនបាន ទទួល ឬដែលខ្លួនអាចនិងបានទទួលពីរាជរដ្ឋាភិបាល កម្ពុជា ឬពីស្ថាប័នណាមួយ រួមទាំងការឧបត្ថម្ភធនមិន ផ្ទាល់ដែលខ្លួនបានទទួល ។

(ង) សេចក្តីពន្យល់អំពីមូលហេតុនៃការកែសម្រួលបញ្ជីថ្លៃ លក់អគ្គិសនី រួមជាមួយនិងភ័ស្តុតាងទាំងឡាយបញ្ជាក់ពីភាពសមស្របនៃទំហំចំណាយ និងអត្រា ចំណេញដែលខ្លួនបានដាក់ស្នើសុំ ។

(ច) របាយការណ៍ចំណូលចំណាយ តារាងតុល្យការ និង របាយការណ៍ហិរញ្ញវត្ថុទៅតាមគំរូដែលបានផ្តល់។ អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនធំត្រូវផ្តល់នូវទិន្នន័យតាមទម្រង់សមស្របដែលមានកំណត់ក្នុង ឧបសម្ព័ន្ធ ទី២។ អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនតូចត្រូវផ្តល់ នូវទិន្នន័យតាមទម្រង់សមស្របដែលមានកំណត់ក្នុង ឧបសម្ព័ន្ធទី៤។

(ឆ) ពត៌មានពាក់ព័ន្ធផ្សេងៗទៀត ទៅតាមការទាមទាររបស់ អាជ្ញាប័ណ្ណ ឬតាមការកំណត់របស់អាជ្ញាធរអគ្គិសនី កម្ពុជា។

(iii) អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនធំត្រូវដាក់ពាក្យស្នើសុំកំណត់បញ្ជីថ្លៃលក់ដោយមានទាំងឯកសារផ្នែករឹងនិងឯកសារផ្នែកទន់។ ជាពិសេសអ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនធំត្រូវបំពេញ ពត៌មាននៅក្នុង ឧបសម្ព័ន្ធទី២ហើយត្រូវផ្តល់ឱ្យអាជ្ញាធរនូវតារាងនោះក្នុងកម្មវិធី MS Excel ។ អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវា-កម្មធុនតូចអាចដាក់ពាក្យស្នើសុំកំណត់បញ្ជីថ្លៃលក់អគ្គិសនីជាឯកសារផ្នែករឹង។

អាជ្ញាធរចង់បានការផ្តល់ទិន្នន័យរបស់អ្នកកាន់-អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនតូចនៅក្នុង ឧបសម្ព័ន្ធទី៤ ជាឯកសារ ផ្អែកទន់ក្នុងកម្មវិធី MS Excel ប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណ នោះមានលទ្ធភាព។

(iv) នៅក្នុងរយៈពេល១០(ដប់)ថ្ងៃ បន្ទាប់ពីថ្ងៃដាក់ពាក្យស្នើសុំ ដោយអ្នកកាន់អាជ្ញាប័ណ្ណ អាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវពិនិត្យ ពាក្យស្នើសុំនេះ និងត្រូវជូនដំណឹងទៅអ្នកកាន់អាជ្ញាប័ណ្ណវិញថា តើពាក្យស្នើសុំនេះសមស្រប និងពេញលេញឬទេ ឬក៏ត្រូវការ ពត៌មានបន្ថែមទៀត។

(v) ក្នុងករណីដែលអាជ្ញាធរអគ្គិសនីកម្ពុជាស្នើសុំផ្តល់ពត៌មានបន្ថែម និងប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណពុំអាចផ្តល់ពត៌មានបន្ថែមណាមួយតាមពេលកំណត់ទេ អ្នកកាន់អាជ្ញាប័ណ្ណអាចស្នើមក អាជ្ញាធរអគ្គិសនីកម្ពុជាសុំពន្យារពេលកំណត់ ឬស្នើសុំលើកលែងការផ្តល់ពត៌មានមួយនោះ។ នៅពេលអាជ្ញាធរអនុញ្ញាតលើក លែង អាជ្ញាធរអាចប្រើប្រាស់ការប៉ាន់ស្មានល្អបំផុតរបស់ខ្លួនជំនួសឱ្យពត៌មានដែលពុំបានផ្តល់នេះ។

(vi) អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនតូចអាចស្នើសុំមកអាជ្ញាធរ លើកលែងចំពោះការផ្តល់ពត៌មានណាមួយនៃពត៌មានទាំងឡាយដែលទាមទារសម្រាប់ការដាក់ពាក្យស្នើសុំ ដូចមានចែងក្នុង មាត្រា២.២(ii) ។

(vii) ក្នុងករណីនោះ ប្រសិនអាជ្ញាធរលើកលែងការផ្តល់ទិន្នន័យ សម្រាប់ការគណនាថ្លៃលក់ស្នើសុំរបស់អ្នកកាន់អាជ្ញាប័ណ្ណធ្វើ សេវាកម្មធុនតូច អាជ្ញាធរអាចសម្រេចបន្តការពិនិត្យបញ្ជីថ្លៃ លក់ឡើងវិញ ដោយផ្អែកលើការគណនា និងការអង្កេតរបស់ ខ្លួន។

## ២.៣. ឯកសារពិនិត្យបញ្ជីថ្លៃលក់អគ្គិសនីឡើងវិញ

ពត៌មាននិងឯកសារទាំងអស់ដែលផ្តល់ដោយអ្នកកាន់អាជ្ញាប័ណ្ណ និងឯកសារ ផ្សេងៗទៀតដែលសម្រេចដោយអាជ្ញាធរអគ្គិសនីកម្ពុជាហៅថា **ឯកសារពិនិត្យបញ្ជីថ្លៃលក់អគ្គិសនី** ។

## ២.៤. ការវាយតម្លៃពាក្យស្នើសុំកំណត់ថ្លៃលក់អគ្គិសនី/ឯកសារ ពិនិត្យបញ្ជីថ្លៃលក់អគ្គិសនីឡើងវិញ ដោយលេខាធិការដ្ឋាន អាជ្ញាធរអគ្គិសនីកម្ពុជា

(i) លេខាធិការដ្ឋានអាជ្ញាធរអគ្គិសនីកម្ពុជានឹងពិនិត្យ និងវាយតម្លៃ ពាក្យស្នើសុំកំណត់បញ្ជីថ្លៃលក់អគ្គិសនីរបស់អ្នកកាន់អាជ្ញាប័ណ្ណ ដោយអនុលោមតាមគោលការណ៍នៃអនុក្រឹត្យ និងបទប្បញ្ញត្តិ។ ក្នុងរយៈពេល០៤(បួន)សប្តាហ៍ បន្ទាប់ពីអាជ្ញាធរទទួលបាន ពត៌មានបន្ថែមទាំងអស់ពីអ្នកកាន់អាជ្ញាប័ណ្ណ ឬនៅពេលដែល អាជ្ញាធរសម្រេចលើកលែងកាតព្វកិច្ចផ្តល់ពត៌មានបន្ថែម លេខា-ធិការដ្ឋានអាជ្ញាធរអគ្គិសនីកម្ពុជានឹងគណនាបញ្ជីថ្លៃលក់អគ្គិសនី រួមជាមួយនឹងសេចក្តីពន្យល់ ដែលជាផ្នែកមួយនៃឯកសារពិនិត្យបញ្ជីថ្លៃលក់ឡើងវិញ។ បញ្ជីថ្លៃលក់អគ្គិសនីនោះត្រូវបាន គណនាដោយផ្អែកលើការអង្កេត និងការគណនាចំណាយ ត្រឹមត្រូវ។

(ii) ក្នុងរយៈពេល០៤(បួន)សប្តាហ៍ បន្ទាប់ពីអាជ្ញាធរលើកលែង កាតព្វកិច្ចផ្តល់ពត៌មានសម្រាប់អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្ម ធុនតូច ដូចមានចែងក្នុងមាត្រា២.២(vii) លេខាធិការដ្ឋាន អាជ្ញាធរអគ្គិសនីកម្ពុជានឹងគណនាបញ្ជីថ្លៃលក់អគ្គិសនី រួមជាមួយនិងសេចក្តីពន្យល់ដែលជាផ្នែកមួយនៃឯកសារពិនិត្យបញ្ជីថ្លៃលក់ ឡើងវិញ។ បញ្ជីថ្លៃលក់អគ្គិសនីនោះត្រូវបានគណនាដោយផ្អែកលើការអង្កេតនិងការគណនាចំណាយត្រឹមត្រូវ ដោយអនុលោម តាមគោលការណ៍នៃអនុក្រឹត្យ និងបទប្បញ្ញត្តិ។

## ២.៥- ថ្ងៃទទួលពាក្យស្នើសុំកំណត់បញ្ជីថ្លៃលក់អគ្គិសនី

នៅពេលដែលលេខាធិការដ្ឋានអាជ្ញាធរបានគណនាថ្លៃលក់អគ្គិសនីដោយផ្អែកលើចំណាយត្រឹមត្រូវរួចហើយ ក្នុងរយៈពេល០៧(ប្រាំពីរ)ថ្ងៃ អាជ្ញាធរត្រូវជូនដំណឹងឱ្យអ្នកកាន់អាជ្ញាប័ណ្ណវិញថា ពាក្យស្នើសុំនោះអាចត្រូវបាន ដាក់ឱ្យដំណើរការហើយ។ ថ្ងៃដែលអាជ្ញាធរជូនដំណឹងឱ្យអ្នកកាន់អាជ្ញាប័ណ្ណតាមមាត្រា២.៥នេះ និងត្រូវចាត់ទុកថាជា **ថ្ងៃទទួលពាក្យស្នើសុំកំណត់ បញ្ជីថ្លៃលក់អគ្គិសនី ក្នុងក្របខ័ណ្ឌនៃច្បាប់** ។

## នីតិវិធី "គ"

## នីតិវិធីសម្រាប់ការពិនិត្យនិងកំណត់បញ្ជីថ្លៃលក់អគ្គិសនីរបស់អ្នកកាន់អាជ្ញាប័ណ្ណ

### ៣.១- គោលបំណងរបស់នីតិវិធី "គ"

(i) នីតិវិធី "គ" គឺជានីតិវិធីដែលត្រូវអនុវត្ត នៅពេលដែល អាជ្ញាធរអគ្គិសនីកម្ពុជាដំណើរការពិនិត្យបញ្ជីថ្លៃលក់អគ្គិសនីឡើងវិញ និងកំណត់បញ្ជីថ្លៃលក់អគ្គិសនីរបស់អ្នកកាន់អាជ្ញាប័ណ្ណ។ នីតិវិធីនេះ គឺជានីតិវិធីអនុវត្តបន្តពីនីតិវិធីណាមួយនៃនីតិវិធីពីរ មុន។

### ៣.២- ការផ្សព្វផ្សាយអំពីការដាក់ពាក្យស្នើសុំ និងឯកសារពិនិត្យបញ្ជី ថ្លៃលក់អគ្គិសនីឡើងវិញ

(i) មិនលើសពីរយៈពេល ១០(ដប់)ថ្ងៃ បន្ទាប់ពីថ្ងៃទទួលពាក្យ ស្នើសុំកំណត់បញ្ជីថ្លៃលក់អគ្គិសនី អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវផ្សព្វផ្សាយសេចក្តីជូនដំណឹងអំពីពាក្យស្នើសុំកំណត់បញ្ជីថ្លៃលក់ អគ្គិសនី/ឯកសារពិនិត្យបញ្ជីថ្លៃលក់អគ្គិសនីឡើងវិញ ដែលមានពត៌មានលម្អិតក្នុងមាត្រាខាងក្រោម។

(ii) សេចក្តីជូនដំណឹងនោះត្រូវស្នើឱ្យអ្នកប្រើប្រាស់ និងអ្នកពាក់ព័ន្ធ ដ៏ទៃទៀត ផ្តល់យោបល់ជាលាយលក្ខណ៍អក្សរលើពាក្យស្នើសុំ/ឯកសារពិនិត្យបញ្ជីថ្លៃលក់អគ្គិសនី និងស្នើឱ្យជូនដំណឹងមក អាជ្ញាធរអគ្គិសនីកម្ពុជា ប្រសិនបើពួកគេចង់ផ្តល់ពត៌មានចំពោះមុខអាជ្ញាធរផ្ទាល់។ សេចក្តីជូនដំណឹងនេះត្រូវមានពត៌មានដូចខាង ក្រោម:

(ក) ឈ្មោះនិងអាសយដ្ឋានរបស់អ្នកកាន់អាជ្ញាប័ណ្ណ និងតំបន់ ធ្វើសេវាកម្មផ្គត់ផ្គង់ដែលត្រូវស្នើសុំកំណត់បញ្ជីថ្លៃលក់ / ត្រូវពិនិត្យបញ្ជីថ្លៃលក់អគ្គិសនីឡើងវិញ

(ខ) បញ្ជីថ្លៃលក់បច្ចុប្បន្ន និងបញ្ជីថ្លៃលក់ស្នើសុំ

(គ) ការគណនាបញ្ជីថ្លៃលក់អគ្គិសនីរបស់លេខាធិការដ្ឋាន អាជ្ញាធរអគ្គិសនីកម្ពុជា

(ឃ) បញ្ជីឯកសារទាំងឡាយដែលមានសម្រាប់សាធារណ-ជនពិនិត្យ

(ង) អាសយដ្ឋានដែលសាធារណជនទូទៅអាចពិនិត្យ ឯកសារនេះ និង

(ច) កាលបរិច្ឆេទចុងក្រោយក្នុងការផ្តល់យោបល់ជាលាយ លក្ខណ៍អក្សរ មកអាជ្ញាធរអគ្គិសនីកម្ពុជា

(iii) មធ្យោបាយផ្សព្វផ្សាយសេចក្តីជូនដំណឹង មានដូចខាងក្រោម:

(ក) បិទផ្សព្វផ្សាយនៅការិយាល័យរបស់អាជ្ញាធរអគ្គិសនី កម្ពុជា ការិយាល័យរបស់អាជ្ញាធរដែនដី ការិយាល័យរបស់អ្នកកាន់អាជ្ញាប័ណ្ណ និងកន្លែងសមស្របដ៏ទៃទៀត និង

(ខ) ផ្សព្វផ្សាយតាមគេហទំព័ររបស់អាជ្ញាធរអគ្គិសនីកម្ពុជា

បូកបន្ថែមមធ្យោបាយណាខាងក្រោមនេះ ដែលប្រធានអាជ្ញាធរអគ្គិសនី កម្ពុជា សម្រេចចាត់ទុកថាសមស្របនឹងកាលៈទេសៈ :

(ក) ចេញផ្សាយពត៌មានតាមរយៈវិទ្យុនិង/ឬទូរទស្សន៍

(ខ) ផ្សព្វផ្សាយសេចក្តីជូនដំណឹងតាមរយៈកាសែត

(គ) ឬវិធីសាស្រ្តណាមួយផ្សេងទៀត

### ៣.៣- សិទ្ធិរបស់សាធារណជនក្នុងការផ្តល់មតិយោបល់លើពាក្យ ស្នើសុំកំណត់បញ្ជីថ្លៃលក់អគ្គិសនី/ឯកសារពិនិត្យបញ្ជីថ្លៃលក់ អគ្គិសនីឡើងវិញ-ការពិគ្រោះយោបល់សាធារណ:

(i) គ្រប់ស្ថាប័នរបស់រាជរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន អ្នកប្រើប្រាស់ អ្នកកាន់អាជ្ញាប័ណ្ណ ឬអ្នកពាក់ព័ន្ធមួយផ្សេងទៀត អាចផ្តល់អនុសាសន៍ជាលាយលក្ខណ៍អក្សរ ឆ្លើយតបនឹងសេចក្តីជូនដំណឹង ចេញដោយអាជ្ញាធរអគ្គិសនីកម្ពុជា ដែលស្នើសុំឱ្យផ្តល់អនុសាសន៍លើពាក្យស្នើសុំកំណត់បញ្ជីថ្លៃលក់អគ្គិសនី ឬលើឯកសារសម្រាប់ ពិនិត្យមើលបញ្ជីថ្លៃលក់អគ្គិសនីឡើងវិញ។ អនុសាសន៍ទាំងនេះត្រូវតែគាំទ្រដោយហេតុផលត្រឹមត្រូវ និងច្បាប់ចម្លងនៃឯកសារ ដ៏ទៃផ្សេងទៀត ដែលជាភ័ស្តុតាងបញ្ជាក់។

(ii) អាជ្ញាធរអគ្គិសនីកម្ពុជាក៏អាចធ្វើការពិគ្រោះយោបល់ជាមួយ បុគ្គលណាមួយ ស្ថាប័នណាមួយ ក្រសួងណាមួយ តាម មធ្យោបាយមួយ ឬច្រើននៃមធ្យោបាយខាងក្រោម ដែលសម្រេច ដោយប្រធានអាជ្ញាធរ៖

(ក) ផ្ញើលិខិតសួរយោបល់

(ខ) ចុះធ្វើសម្ភាសន៍

(គ) អញ្ជើញ បុគ្គល ស្ថាប័ន និងភាគីដែលពាក់ព័ន្ធបញ្ហានេះ មកពិភាក្សា និងផ្តល់យោបល់។

(iii) ក្នុងគ្រប់ករណីដែលមានក្នុងវាក្យខ័ណ្ឌ (ii) អាជ្ញាធរអគ្គិសនី កម្ពុជាត្រូវរក្សាទុកឯកសារផ្តល់យោបល់របស់ភាគីទីបី ជាលាយលក្ខណ៍អក្សរដែលមានហត្ថលេខារបស់អ្នកផ្តល់យោបល់ ឬដោយ ប្រធានអង្គប្រជុំ ។

(iv) រយៈពេលពីថ្ងៃផ្សព្វផ្សាយសេចក្តីជូនដំណឹងអំពីពាក្យស្នើសុំ កំណត់បញ្ជីថ្លៃលក់ឬការត្រួតពិនិត្យបញ្ជីថ្លៃលក់ឡើងវិញ ដែលមានកំណត់ក្នុងមាត្រា៣.២នៃនីតិវិធីនេះ រហូតដល់ថ្ងៃកំណត់ ចុងក្រោយក្នុងការផ្តល់ពត៌មានជាលាយលក្ខណ៍អក្សរដែលមានកំណត់ក្នុងលិខិតជូនដំណឹងហៅថា **“រយៈពេលពិគ្រោះយោបល់សាធារណៈ”**។

(v) រយៈពេលពិគ្រោះយោបល់សាធារណៈ ត្រូវសម្រេចដោយ ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជាសម្រាប់ករណីនីមួយៗ ប៉ុន្តែមិន ត្រូវតិចជាង ៣០(សាមសិប) ថ្ងៃឡើយ។

## ៣.៤- ឯកសារដែលត្រូវមានសម្រាប់សាធារណជនពិនិត្យ

ពាក្យស្នើសុំកំណត់បញ្ជីថ្លៃលក់អគ្គិសនីឬឯកសារពិនិត្យថ្លៃលក់អគ្គិសនីឡើង វិញរួមជាមួយនឹងពត៌មានដែលមិនគ្រប់គ្រាន់ទាំងឡាយ និងពត៌មានផ្សេងទៀតដែលអ្នកកាន់អាជ្ញាប័ណ្ណបានផ្តល់ឱ្យជាបន្តបន្ទាប់ត្រូវតែមានសម្រាប់ដាក់ជូនសាធារណជនពិនិត្យក្នុងកំឡុងពេលពិគ្រោះយោបល់សាធារណៈ។ ប៉ុន្តែប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណណាមួយស្នើសុំរក្សាទុកពត៌មានមួយចំនួនជា ពត៌មានសម្ងាត់ ហើយអាជ្ញាធរអគ្គិសនីកម្ពុជាយល់ថាពត៌មានណាមួយនោះជាពត៌មានសម្ងាត់ ពត៌មាននោះអាចដកចេញពីឯកសារដែលត្រូវដាក់ឱ្យ សាធារណជនពិនិត្យដោយសេរី។ អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវរៀបចំយ៉ាងណា ដើម្បីឱ្យអ្នកពាក់ព័ន្ធអាចពិនិត្យឯកសារទាំងនេះបាន ដោយសេរី នៅ ក្នុងម៉ោងធ្វើការងារធម្មតា ដោយគ្មានបង់ប្រាក់ តាមកន្លែងដូចខាងក្រោម ៖

(ក) ទីស្នាក់ការរបស់អាជ្ញាធរអគ្គិសនីកម្ពុជា

(ខ) ទីស្នាក់ការរបស់អ្នកកាន់អាជ្ញាប័ណ្ណ

(គ) ទីស្នាក់ការរបស់អាជ្ញាធរមូលដ្ឋានដែលពាក់ព័ន្ធ និង

(ឃ) កន្លែងណាមួយផ្សេងទៀតដែលសម្រេចដោយប្រធានអាជ្ញាធរ

## ៣.៥- ការវាយតម្លៃលើការផ្តល់យោបល់របស់សាធារណជន និងការទទួលពត៌មានបន្ថែម

(i) អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវត្រួតពិនិត្យ និងវាយតម្លៃអនុសាសន៍ ទាំងឡាយដែលទទួលបានក្នុងដំណើរការនៃការពិគ្រោះយោបល់សាធារណៈ។ អាជ្ញាធរអគ្គិសនីកម្ពុជាអាចតម្រូវឱ្យអ្នកកាន់-អាជ្ញាប័ណ្ណឬបុគ្គលណាមួយផ្សេងទៀត ផ្តល់ពត៌មាន សេចក្តីបំភ្លឺ និងភ័ស្តុតាងជាក់លាក់បន្ថែមទៀត ទាក់ទងនឹងអនុសាសន៍របស់ អ្នកដែលផ្តល់យោបល់នោះ ។ អាជ្ញាធរអាចទទួលពត៌មាន ខាងលើនេះជាលាយលក្ខណ៍អក្សរ ឬតាមរយៈការពិភាក្សា ប៉ុន្តែក្នុងករណីផ្តល់ឱ្យតាមរយៈការពិភាក្សាត្រូវមានកំណត់ហេតុនៃការពិភាក្សាជាលាយលក្ខណ៍អក្សរដែលមានចុះហត្ថលេខា ដោយអ្នកផ្តល់ពត៌មាន។

(ii) អាជ្ញាធរអគ្គិសនីកម្ពុជាអាចស្នើឱ្យអ្នកកាន់អាជ្ញាប័ណ្ណផ្តល់ពត៌មានបន្ថែម ដែលត្រូវការសម្រាប់វាយតម្លៃអនុសាសន៍របស់ សាធារណជន និងវាយតម្លៃពាក្យស្នើសុំកំណត់បញ្ជីថ្លៃលក់/ ឯកសារសម្រាប់ពិនិត្យបញ្ជីថ្លៃលក់អគ្គិសនីឡើងវិញ ។ អាជ្ញាធរអគ្គិសនីកម្ពុជានឹងកំណត់រយៈពេលមួយដែលអ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្តល់ពត៌មានបន្ថែម។ រយៈពេលកំណត់នោះនឹងត្រូវកំណត់ដោយអាជ្ញាធរអគ្គិសនីកម្ពុជា ប៉ុន្តែមិនត្រូវតិចជាង១៥ (ដប់ប្រាំ) ថ្ងៃ ចាប់ពីថ្ងៃដែលអ្នកកាន់អាជ្ញាប័ណ្ណទទួលពត៌មានលម្អិតពីការផ្តល់អនុសាសន៍របស់សាធារណជន ។

**៣.៦- ការវាយតម្លៃការស្នើសុំកំណត់បញ្ជីថ្លៃលក់អគ្គិសនីឬឯកសារពិនិត្យ បញ្ជីថ្លៃលក់ឡើងវិញ ដោយអាជ្ញាធរ**

អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវវាយតម្លៃការស្នើសុំកំណត់បញ្ជីថ្លៃលក់អគ្គិសនី ឬ ឯកសារពិនិត្យបញ្ជីថ្លៃលក់អគ្គិសនីឡើងវិញ ដោយផ្អែកលើអនុសាសន៍ទាំងឡាយ និងពត៌មានដ៏ទៃទៀតទាំងអស់ដែលទទួលបាន ។

**៣.៧- ការបើកសវនាការពិគ្រោះយោបល់របស់អាជ្ញាធរអគ្គិសនីកម្ពុជា**

អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវបើកសវនាការពិគ្រោះយោបល់ជាមួយអ្នកស្នើសុំ ផ្តល់យោបល់នៅចំពោះមុខ មានដូចជាអ្នកកាន់អាជ្ញាប័ណ្ណ, មន្ត្រីអាជ្ញាធរអគ្គិសនីកម្ពុជា និងអ្នកពាក់ព័ន្ធផ្សេងទៀត ដែលកំណត់ដោយអាជ្ញាធរ។ អាជ្ញាធរត្រូវពិចារណាលើការពិតទាំងអស់ដែលបានទទួល ដើម្បីធ្វើការសម្រេចចិត្តចំពោះបញ្ជីថ្លៃលក់អគ្គិសនីដែលស្នើសុំ ឬការពិនិត្យបញ្ជីថ្លៃលក់ អគ្គិសនីឡើងវិញ ។

**៣.៨- សម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជា**

(i) ក្នុងរយៈពេល ៩០ (កៅសិប) ថ្ងៃ បន្ទាប់ពីថ្ងៃទទួលពាក្យស្នើសុំ កំណត់បញ្ជីថ្លៃលក់ អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវប្រកាសសេចក្តីសម្រេចអំពីថ្លៃលក់ស្នើសុំ នៅក្នុងសម័យប្រជុំរបស់អាជ្ញាធរ ។

**៣.៩- សេចក្តីសម្រេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជា**

(i) សេចក្តីសម្រេចនោះត្រូវមានទម្រង់មួយនៃទម្រង់ខាងក្រោម ហើយនៅគ្រប់ករណី អាជ្ញាធរត្រូវផ្សព្វផ្សាយសេចក្តីសម្រេច នោះដោយមានសេចក្តីពន្យល់អំពីសេចក្តីសម្រេចនោះ :

(ក) អាជ្ញាធរអគ្គិសនីកម្ពុជាសម្រេចអនុម័តចំពោះបញ្ជីថ្លៃ លក់អគ្គិសនីដែលបានស្នើក្នុងពាក្យស្នើសុំកំណត់បញ្ជីថ្លៃលក់ និងកំណត់ខ្លឹមសារលម្អិតនៃបញ្ជីថ្លៃលក់ថ្មីដែល បានអនុម័តនេះ ជាមួយនិងល័ក្ខខ័ណ្ឌទាំងអស់ដែលត្រូវ អនុវត្ត និងកាលបរិច្ឆេទដែលបញ្ជីថ្លៃលក់អគ្គិសនីថ្មីត្រូវ មានប្រសិទ្ធភាពអនុវត្ត ។

**ឬ**

(ខ) អាជ្ញាធរអគ្គិសនីកម្ពុជាសម្រេចមិនយល់ព្រមចំពោះ បញ្ជីថ្លៃលក់ដែលស្នើក្នុងពាក្យស្នើសុំរបស់អ្នកកាន់អាជ្ញាប័ណ្ណឡើយ ក្នុងករណីនេះ បញ្ជីថ្លៃលក់និងល័ក្ខខ័ណ្ឌ ទាំងអស់ដែលកំពុងតែអនុវត្តនឹងត្រូវបន្តអនុវត្តដដែល ។

**ឬ**

(គ) អាជ្ញាធរអគ្គិសនីកម្ពុជាសម្រេចកែសម្រួលបញ្ជីថ្លៃលក់ ឡើងវិញ ក្នុងករណីនេះ សេចក្តីសម្រេចត្រូវមានលម្អិតអំពីបញ្ជីថ្លៃលក់ថ្មីដែលកែសម្រួល រួមជាមួយនិងល័ក្ខខ័ណ្ឌ ទាំងអស់ដែលត្រូវអនុវត្ត និងកាលបរិច្ឆេទដែលបញ្ជីថ្លៃលក់ថ្មីត្រូវមានប្រសិទ្ធភាពអនុវត្ត ។

(ii) សេចក្តីសម្រេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជានៅក្នុងវាក្យខ័ណ្ឌទី (i)(គ) នៃមាត្រា៣.៨ នេះ ដើម្បីកែសម្រួលបញ្ជីថ្លៃលក់ អគ្គិសនីអាចជាសេចក្តីសម្រេចមួយឆ្លើយតបទៅនឹងពាក្យស្នើ សុំរបស់អ្នកកាន់អាជ្ញាប័ណ្ណ ឬក៏ជាសេចក្តីសម្រេចពិនិត្យបញ្ជីថ្លៃលក់ឡើងវិញដោយអាជ្ញាធរផ្ទាល់។

(iii) មធ្យោបាយផ្សព្វផ្សាយសេចក្តីសម្រេចរបស់អាជ្ញាធរអគ្គិសនី–កម្ពុជា ក្នុងក្របខ័ណ្ឌនៃមាត្រា៣.៨ ត្រូវដូចគ្នានឹងមធ្យោបាយដែលអាជ្ញាធរបានកំណត់សម្រាប់ការផ្សព្វផ្សាយអំពីពាក្យស្នើសុំ កំណត់បញ្ជីថ្លៃលក់ដែលមានក្នុងមាត្រា៣.២ (iv) ។

**៣.១០– ពត៌មានអំពីបញ្ជីថ្លៃលក់**

(i) អ្នកកាន់អាជ្ញាប័ណ្ណត្រូវរក្សាទុកច្បាប់ចម្លងនៃឯកសារបញ្ជីថ្លៃលក់ អគ្គិសនីបច្ចុប្បន្ន ជាមួយនិងល័ក្ខខ័ណ្ឌទាំងអស់ដែលត្រូវអនុវត្តសម្រាប់អ្នកពាក់ព័ន្ធទាំងឡាយ ពិនិត្យដោយសេរី ដោយមិន គិតថ្លៃ ក្នុងម៉ោងធ្វើការធម្មតា នៅការិយាល័យរបស់ខ្លួនទាំង អស់។

## ឧបសម្ព័ន្ធទី ១

## ការផ្តល់ទិន្នន័យប្រចាំឆ្នាំរបស់អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនធំ

អ្នកកាន់អាជ្ញាប័ណ្ណទាំងអស់ដែលអាជ្ញាធរអគ្គិសនីកម្ពុជាកំណត់ថាជាអ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនធំ ត្រូវផ្តល់ទិន្នន័យនិងពត៌មានផ្សេងៗដែលមានចែងនៅក្នុង ឧបសម្ព័ន្ធនេះសម្រាប់ឆ្នាំការិយបរិច្ឆេទមុន មិនឱ្យហួសថ្ងៃទី៣១ មីនា ជារៀងរាល់ឆ្នាំ ។

**គំរូទិន្នន័យហិរញ្ញវត្ថុ**

**១– អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនធំ: ចំណាយដំណើរការនិង ការថែទាំ**

អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្តល់ទិន្នន័យលម្អិតអំពីចំណាយដំណើរការ និងការ ថែទាំជាក់ស្តែងរបស់ខ្លួន, ចំណាយទិញប្រេងឥន្ធនៈ, ចំណាយរដ្ឋបាលនិងការគ្រប់គ្រងទូទៅ និងចំណាយទិញថាមពល ដូចដែលមានកំណត់ នៅក្នុងតារាងAL1 ដល់តារាង AL6 ។

**២– អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនធំ: ពត៌មានអំពីមូលធនជាក់ស្តែង ផ្ទាល់**

(i) អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្តល់នូវខ្លឹមសារលម្អិតនៃការគណនាខ្ទង់ មូលធនជាក់ស្តែងផ្ទាល់នីមួយៗ និងភ្ជាប់ជាមួយនូវទិន្នន័យហិរញ្ញវត្ថុនិងបច្ចេកទេស ។ ប្រសិនបើផ្នែកណាមួយនៃមូលធន ជាក់ស្តែងផ្ទាល់ត្រូវបានប្រើប្រាស់នៅ ឬត្រូវបានផ្តល់ហិរញ្ញវត្ថុពីសកម្មភាពផ្សេង ក្រៅពីសកម្មភាពដែលមានចែងនៅក្នុងអាជ្ញា–ប័ណ្ណ ពត៌មានលម្អិតនោះត្រូវផ្តល់ឱ្យអាជ្ញាធរអគ្គិសនីកម្ពុជា ។

(ii) ពត៌មានដែលត្រូវផ្តល់ឱ្យអាជ្ញាធរត្រូវមានដូចគំរូក្នុងតារាងAL7 ដល់ AL11 និងត្រូវផ្តល់ខ្លឹមសារលម្អិតភ្ជាប់ជាមួយ ដូចខាង ក្រោម:

- ប្រាក់កម្ចីដែលប្រើប្រាស់សម្រាប់អាជីវកម្មរបស់អ្នកកាន់–អាជ្ញាប័ណ្ណ
- អចលនទ្រព្យ
- រំលោះ
- អចលនទ្រព្យដែលកំពុងសាងសង់
- ការបែងចែករវាងមូលធនផ្ទាល់និងជំនួយលើទ្រព្យមូលធន: អ្នកកាន់អាជ្ញាប័ណ្ណត្រូវផ្តល់ពត៌មានអំពីចំណែកនៃមូលធនរបស់ខ្លួនផ្ទាល់ទៅក្នុងអាជីវកម្មរបស់ខ្លួនតាមអាជ្ញាប័ណ្ណ និងជំនួយពីស្ថាប័នផ្សេងៗ ទៅលើទ្រព្យមូលធន ។

**៣– អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនធំ: ទ្រព្យសកម្មរយៈពេលខ្លី និង បំណុលរយៈពេលខ្លី**

អ្នកកាន់អាជ្ញាប័ណ្ណត្រូវផ្តល់នូវពត៌មានលម្អិតអំពីទ្រព្យសកម្មរយៈពេលខ្លី និង បំណុលរយៈពេលខ្លី តាមគំរូតារាងAL12។ ពត៌មាននេះរួមមានបំណុលទិញថាមពល និងបំណុលប្រេងឥន្ធនៈ រួមទាំងឯកសារយោងផ្សេងៗផង។

**៤– អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនធំ: អត្រាប្រាក់ចំណេញសមស្រប លើមូលធនជាក់ស្តែងផ្ទាល់ដែលបានប្រើប្រាស់**

អ្នកកាន់អាជ្ញាប័ណ្ណត្រូវបង្ហាញនូវការគណនាអត្រាប្រាក់ចំណេញពិតប្រាកដ លើមូលធនជាក់ស្តែងផ្ទាល់ តាមគំរូដែលមាននៅក្នុងតារាង AL13 នៃឧបសម្ព័ន្ធនេះ។ ចំពោះសំវិធានធនសម្រាប់ទុនចល័ត ត្រូវផ្តល់នូវការ ពន្យល់អំពីការគណនាទុនចល័តនោះ។

**៥- អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនធំ៖ ចំណូលផ្សេងក្រៅពីប្រភព ថ្លៃលក់អគ្គិសនី**

អ្នកកាន់អាជ្ញាប័ណ្ណត្រូវបង្ហាញពីចំណូលជាក់ស្តែងក្រៅពីប្រភពចំណូលតាម រយៈការលក់អគ្គិសនីតាមតារាង AL14 នៃឧបសម្ព័ន្ធនេះ ។ មិនត្រូវបញ្ចូលចំណូលពីអាជីវកម្មផ្សេង ក្រៅពីអាជីវកម្មដែលកំណត់ក្នុងអាជ្ញាប័ណ្ណ ទៅក្នុងតារាងAL14 នៃឧបសម្ព័ន្ធនេះឡើយ។

**៦- អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនធំ៖ ចំណូលប៉ាន់ស្មានពីការលក់ អគ្គិសនី**

អ្នកកាន់អាជ្ញាប័ណ្ណត្រូវគណនាចំណូលដែលប្រមូលបានពីការលក់អគ្គិសនីនៅឆ្នាំមុន តាមទម្រង់ក្នុងតារាង AL15 នៃឧបសម្ព័ន្ធនេះ។

**តារាងសង្ខេប**

**៧- អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនធំ៖ កម្រិតនៃចំណាយត្រឹមត្រូវ**

អ្នកកាន់អាជ្ញាប័ណ្ណត្រូវបង្ហាញនូវកម្រិតនៃចំណាយត្រឹមត្រូវនៅក្នុងឆ្នាំការិយ-បរិច្ឆេទមុន តាមទម្រង់ដែលមានក្នុងតារាង S1 នៃឧបសម្ព័ន្ធនេះ។ ចំណូលផ្សេងៗក្រៅពីការលក់អគ្គិសនី ត្រូវដកចេញពីការគណនាចំណាយ ត្រឹមត្រូវសុទ្ធ។

**៨- អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនធំ៖ របាយការណ៍លំហូរ សាច់ប្រាក់ និងតារាងតុល្យការ**

អ្នកកាន់អាជ្ញាប័ណ្ណត្រូវផ្តល់ខ្លឹមសារលម្អិតអំពីតារាងតុល្យការ និងរបាយ-ការណ៍ លំហូរសាច់ប្រាក់សម្រាប់ឆ្នាំការិយបរិច្ឆេទមុនដែលបានធ្វើសវនកម្មរួច នៅក្នុងតារាង S2 និងតារាង S3។ ប្រសិនបើរបាយការណ៍ដែល ធ្វើសវនកម្មរួចមិនទាន់មាន ដោយសារតែការធ្វើសវនកម្មមិនទាន់ចប់ ពេលនោះអាចផ្តល់គណនីដែលមិនទាន់ធ្វើសវនកម្មសម្រាប់ឆ្នាំការិយបរិច្ឆេទ មុននេះបាន។ ប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណមិនអាចមានគណនីដែលបានធ្វើសវនកម្ម ដោយសារមូលហេតុណាមួយដែលយល់ព្រមដោយអាជ្ញាធរ អគ្គិសនីកម្ពុជា ពេលនោះអ្នកកាន់អាជ្ញាប័ណ្ណត្រូវផ្តល់ឱ្យអាជ្ញាធរនូវគណនីដើម្បីឱ្យអាជ្ញាធរត្រួតពិនិត្យអនុលោមតាមល័ក្ខខ័ណ្ឌអាជ្ញាប័ណ្ណ។ ក្នុងករណី នេះ ជំនួសឱ្យគណនីដែលបានធ្វើសវនកម្មរួច អ្នកកាន់អាជ្ញាប័ណ្ណអាចផ្តល់នូវគណនីដែលត្រូវបានត្រួតពិនិត្យរួចដោយអាជ្ញាធរអគ្គិសនីកម្ពុជាបាន ។

**តារាងប្រតិបត្តិ**

មាត្រា ៤៨ នៃច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ចែងថា "បញ្ជីថ្លៃលក់អគ្គិសនី ដែលកំណត់ដោយអាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវលើកទឹកចិត្តចំពោះប្រសិទ្ធភាពនៃកិច្ចប្រតិបត្តិការ និងការគ្រប់គ្រងផ្ទៃក្នុងរបស់ អ្នកកាន់អាជ្ញាប័ណ្ណនិងប្រសិទ្ធភាពសេដ្ឋកិច្ចក្នុងវិស័យអគ្គិសនី"។ ក្នុងបរិបទនេះ អ្នកកាន់អាជ្ញាប័ណ្ណត្រូវផ្តល់នូវរបាយការណ៍អំពីសូចនាករ ប្រតិបត្តិការ ដូចខាងក្រោម៖

**៩- អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនធំ៖ ការវិភាគអាយុនៃបំណុល**

អ្នកកាន់អាជ្ញាប័ណ្ណត្រូវផ្តល់ពត៌មានលម្អិតអំពីចំនួនបំណុលមិនទាន់បង់នៅ ដើមឆ្នាំ និងនៅចុងឆ្នាំដោយវិភាគតាមអាយុនៃបំណុល។ អ្នកកាន់អាជ្ញាប័ណ្ណត្រូវផ្តល់ពត៌មានអំពីមូលហេតុនៃការប្រមូលមិនបាន និងស្ថានភាពនៃការ អនុវត្តច្បាប់ពាក់ព័ន្ធនឹងការប្រមូលបំណុលដែលមានចំនួន ៥០០,០០០រៀល ឬច្រើនជាងនេះ មិនបាន ។

**១០- អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនធំ៖ ពត៌មានអំពីថាមពល**

អ្នកកាន់អាជ្ញាប័ណ្ណត្រូវផ្តល់នូវរបាយការណ៍ថាមពលប្រចាំខែ រួមទាំងការ បាត់បង់លើបណ្តាញបញ្ជូន និងបណ្តាញចែកចាយផងដែរ ។ អ្នកកាន់-អាជ្ញាប័ណ្ណត្រូវផ្តល់ពត៌មានលម្អិតអំពីថាមពលលក់ ដោយបែងចែកដាច់ពីគ្នា រវាងផ្នែកតង់ស្យុងមធ្យម និងតង់ស្យុងទាប និងពត៌មានថាមពលផលិត ឬទិញពីប្រភពផ្សេងៗផងដែរ ។

**១១- អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនធំ៖ ប៉ារ៉ាម៉ែត្រផ្សេងៗទៀត**

អ្នកកាន់អាជ្ញាប័ណ្ណត្រូវផ្តល់ខ្លឹមសារលម្អិតដូចខាងក្រោមតាមតារាង P3ដល់ តារាងP5 ដើម្បីបង្កការងាយស្រួលដល់ការពិភាក្សាអំពីការអនុវត្តរបស់អ្នកកាន់អាជ្ញាប័ណ្ណក្នុងចំណោមអ្នកពាក់ព័ន្ធទាំងអស់ ក្នុងអំឡុងពេលពិគ្រោះ យោបល់។ ពត៌មានទាំងនេះ រួមមាន៖

- ខ្លឹមសារលម្អិតអំពីឧប្បត្តិហេតុរបស់ត្រង់ស្វូរ

- ចំនួនករណីគ្រោះថ្នាក់ដោយចរន្តអគ្គិសនី ដោយចែកជា: ករណីមានស្លាប់ និងករណីមិនមាន ស្លាប់ និង
- ការភ្ជាប់ចរន្តថ្មី ។

## ឧបសម្ព័ន្ធទី ២
## ការស្នើសុំកែសម្រួលបញ្ជីថ្លៃលក់អគ្គិសនីរបស់អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនធំ

ប្រសិនបើ អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនធំស្នើសុំមកអាជ្ញាធរអគ្គិសនី កម្ពុជា ដើម្បី :

(ក) កែសម្រួលអត្រាថ្លៃលក់អគ្គិសនីឡើងវិញទាំងអស់ ឬក៏កែ សម្រួលអត្រាថ្លៃលក់អគ្គិសនីណាមួយ និង/ឬ

(ខ) កំណត់បញ្ជីថ្លៃលក់អគ្គិសនីថ្មី ឬកំណត់អត្រាថ្លៃលក់ថ្មី

ពេលនោះអ្នកកាន់អាជ្ញាប័ណ្ណត្រូវផ្តល់ឱ្យអាជ្ញាធរអគ្គិសនីកម្ពុជានូវទិន្នន័យ តាមទម្រង់ដែលមានចែងក្នុង ឧបសម្ព័ន្ធនេះ ដែលពាក់ព័ន្ធនឹងឆ្នាំកំពុងអនុវត្ត និងឆ្នាំបន្ទាប់ ។ ទិន្នន័យសម្រាប់ឆ្នាំកំពុងអនុវត្តត្រូវផ្អែកលើតួលេខពិតប្រាកដ តាមខែនីមួយៗសម្រាប់ឆ្នាំ និងតួលេខប៉ាន់ស្មានសម្រាប់ខែនៅសល់នៃឆ្នាំនេះ ។

### គំរូទិន្នន័យហិរញ្ញវត្ថុ

### ១- អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនធំ : ពត៌មានអំពីចំណាយត្រឹមត្រូវ និងបញ្ជីថ្លៃលក់អគ្គិសនី

ពត៌មានដែលត្រូវផ្តល់ដោយអ្នកកាន់អាជ្ញាប័ណ្ណ ដែលជាផ្នែកមួយនៃ ឧបសម្ព័ន្ធនេះ ត្រូវមាន :

(ក) ចំណាយត្រឹមត្រូវ, មូលធនដាក់ស្តែងផ្ទាល់, ចំណូល ផ្សេងពីថ្លៃលក់នៅឆ្នាំកំពុងអនុវត្ត និងឆ្នាំបន្ទាប់ដូចគំរូក្នុង តារាង TL 1 រហូតដល់ TL 13 នៃឧបសម្ព័ន្ធនេះ ។ កម្រិតចំណាយត្រឹមត្រូវសម្រាប់ឆ្នាំបន្ទាប់ ត្រូវគិតដល់ អតិរេកនៃចំណូលនៅឆ្នាំការិយបរិច្ឆេទមុន ។

(ខ) ការប៉ាន់ស្មានចំណូលពេញមួយឆ្នាំ តាមអត្រាថ្លៃលក់ បច្ចុប្បន្នសម្រាប់ឆ្នាំកំពុងអនុវត្ត និងឆ្នាំបន្ទាប់ ពត៌មាន ទាំងនេះត្រូវផ្តល់ឱ្យតាមគំរូតារាង TL 14 នៃឧបសម្ព័ន្ធ នេះ ។ ពត៌មានទាំងនេះរួមមានរបាយការណ៍បរិមាណ ថាមពលតាមប្រភេទថ្លៃលក់នីមួយៗនិងឯកសារយោង ។ អ្នកកាន់អាជ្ញាប័ណ្ណត្រូវផ្តល់នូវខ្លឹមសារលម្អិតអំពីចំនួនអ្នក ប្រើប្រាស់តាមប្រភេទថ្លៃលក់នីមួយៗ របាយការណ៍អំពី បរិមាណថាមពលដែលបានប្រើប្រាស់ឬថាមពលប៉ាន់ស្មាន សម្រាប់ការផ្គត់ផ្គង់ដោយគ្មានទាឡិកាស្ទង់ណាមួយ និង បរិមាណថាមពលប្រើប្រាស់ក្នុងកម្រិតការទូទាត់អប្បរមា ប្រសិនបើមាន ។

(គ) របាយការណ៍ស្តីពីប្រាក់ចំណូលរំពឹងទុកពេញ១ឆ្នាំ តាម ថ្លៃលក់អគ្គិសនីដែលបានស្នើសុំសម្រាប់ឆ្នាំកំពុងអនុវត្ត ។ របាយការណ៍នេះត្រូវផ្តល់ឱ្យតាមគំរូតារាង TL 15 នៃ ឧបសម្ព័ន្ធនេះ ។

(ឃ) របាយការណ៍ស្តីពីផលប៉ះពាល់នៃថ្លៃលក់អគ្គិសនីដែល បានស្នើសុំ លើប្រភេទអ្នកប្រើប្រាស់នីមួយៗទៅតាមគំរូ តារាង TL 16 ។

(ង) ពត៌មានផ្សេងៗទៀត ដែលត្រូវការទាក់ទងនឹងអាជ្ញាប័ណ្ណ ឬកំណត់ដោយអាជ្ញាធរអគ្គិសនីកម្ពុជា ។

### ២- អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនធំ : ពត៌មានផ្សេងៗ

(ក) របាយការណ៍ស្តីពីការគណនាចំនួនប្រាក់ឧបត្ថម្ភធន នៅ ក្នុងបញ្ជីថ្លៃលក់ដែលកំពុងអនុវត្ត និងបញ្ជីថ្លៃលក់ដែល ស្នើសុំ ។ របាយការណ៍នេះត្រូវផ្តល់ឱ្យតាមគំរូតារាង TL 17 នៃឧបសម្ព័ន្ធនេះ ។

(ខ) ការកាត់បន្ថយការបាត់បង់ថាមពលចែកចាយ គឺជា គោលដៅសំខាន់របស់អ្នកកាន់អាជ្ញាប័ណ្ណ ហើយការ កំណត់ថ្លៃលក់អគ្គិសនី ចាំបាច់ត្រូវពិចារណាអំពីការបាត់ បង់ និងការកាត់បន្ថយណាមួយក្នុងការបាត់បង់នោះ ។ ដូច្នេះ គំរូតារាង TL 18 រួមមានពត៌មានលម្អិតអំពី ថាមពលលក់ប៉ាន់ស្មាន និងថាមពលផលិត/ទិញដែល គណនាដោយយោងតាមតួលេខបាត់បង់ដែលបាន ព្យាករណ៍ទុក ។

**តារាងសង្ខេប**

**១- អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនធំ៖ កម្រិតចំណាយត្រឹមត្រូវ**

អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវបង្ហាញនូវកម្រិតចំណាយត្រឹមត្រូវនៅក្នុងឆ្នាំការិយ បរិច្ឆេទកំពុងអនុវត្ត និងឆ្នាំបន្ទាប់ តាមគំរូតារាង S1 នៃឧបសម្ព័ន្ធនេះ ដែលរំពឹងថានឹងប្រមូលបានពីថ្លៃលក់។ ចំណូលផ្សេងក្រៅពីប្រភពការលក់ អគ្គិសនី ត្រូវដកចេញពីការគណនាចំណាយត្រឹមត្រូវសុទ្ធ។

**២- អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនធំ៖ របាយការណ៍លំហូរ សាច់ប្រាក់ និងតារាងតុល្យការ**

អ្នកកាន់អាជ្ញាប័ណ្ណត្រូវផ្តល់ពត៌មានលម្អិតអំពីតារាងតុល្យការ និងរបាយ–ការណ៍លំហូរសាច់ប្រាក់សម្រាប់ឆ្នាំការិយបរិច្ឆេទកំពុងអនុវត្ត ដែលបានធ្វើសវនកម្មរួច តាមគំរូតារាង S2 និងតារាង S3។

## ឧបសម្ព័ន្ធទី ៣

## ការផ្តល់ទិន្នន័យប្រចាំឆ្នាំរបស់អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនតូច

អ្នកកាន់អាជ្ញាប័ណ្ណទាំងអស់ដែលអាជ្ញាធរអគ្គិសនីកម្ពុជាកំណត់ថាជាអ្នកកាន់ អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនតូច ត្រូវផ្តល់ទិន្នន័យ និងពត៌មានផ្សេងៗនៅឆ្នាំការិយបរិច្ឆេទមុន ដែលមានចែងនៅក្នុងឧបសម្ព័ន្ធនេះ មិនឱ្យហួសថ្ងៃទី៣១ មីនា ជារៀងរាល់ឆ្នាំ ។

**១- អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនតូច៖ ចំណាយដំណើរការ និងការថែទាំ**

អ្នកកាន់អាជ្ញាប័ណ្ណត្រូវផ្តល់ទិន្នន័យលម្អិតអំពីចំណាយដំណើរការ និងការ ថែទាំ, ចំណាយទិញប្រេងឥន្ទនៈ, ចំណាយរដ្ឋបាល និងការគ្រប់គ្រងទូទៅ និងចំណាយទិញថាមពល និងឯកសារយោងដែលមានកំណត់នៅ ក្នុងគំរូតារាង AS1 ដល់ AS5 ឧបសម្ព័ន្ធនេះ។

**២- អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនតូច៖ ពត៌មានអំពីមូលធន ជាក់ស្តែងផ្ទាល់**

អ្នកកាន់អាជ្ញាប័ណ្ណត្រូវផ្តល់ទិន្នន័យអំពីមូលធនជាក់ស្តែងផ្ទាល់ តាមគំរូតារាង AS6 ដល់ AS8 ។ ពត៌មានទាំងនេះ រួមមានពត៌មានលម្អិតអំពីអចលនទ្រព្យសុទ្ធ, រំលោះបូកយោង និងបំណុល។

**៣- អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនតូច៖ អត្រាប្រាក់ចំណេញសម ស្របលើមូលធនជាក់ស្តែងផ្ទាល់**

អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវបង្ហាញនូវការគណនាអត្រាប្រាក់ចំណេញពិតប្រាកដ លើមូលធនជាក់ស្តែងផ្ទាល់ តាមគំរូតារាង AS9 នៃឧបសម្ព័ន្ធនេះ។ ចំពោះសំវិធានធនសម្រាប់ទុនចល័ត ត្រូវផ្តល់នូវការពន្យល់អំពីការគណនា ទុនចល័តនោះ។

**៤- អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនតូច៖ ចំណាយត្រឹមត្រូវ**

អ្នកកាន់អាជ្ញាប័ណ្ណត្រូវបង្ហាញនូវកម្រិតចំណាយត្រឹមត្រូវនៅឆ្នាំការិយបរិ–ច្ឆេទមុន តាមគំរូដែលមាននៅក្នុងតារាង AS10 នៃឧបសម្ព័ន្ធនេះ ។

**៥- អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនតូច៖ ចំណូលពីការលក់បច្ចុប្បន្ន**

អ្នកកាន់អាជ្ញាប័ណ្ណត្រូវបង្ហាញនូវការគណនាចំណូលពីការលក់ពិតប្រាកដ នៅឆ្នាំការិយបរិច្ឆេទមុន តាមគំរូតារាង AS11 នៃឧបសម្ព័ន្ធនេះ ។ ការផ្តល់នេះ រួមមានបរិមាណថាមពលតាមប្រភេទថ្លៃលក់នីមួយៗដែល ព្យាករណ៍ និងឯកសារយោងជាមួយផង។

**៦- អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនតូច៖ ពត៌មានអំពីថាមពល**

អ្នកកាន់អាជ្ញាប័ណ្ណត្រូវបង្ហាញនូវពត៌មានលម្អិតអំពីថាមពលលក់ពិតប្រាកដ ថាមពលទិញ ថាមពលផលិត និងថាមពលបាត់បង់ តាមគំរូតារាង AS12 នៃឧបសម្ព័ន្ធនេះ ។

## ឧបសម្ព័ន្ធទី ៤

## ការស្នើសុំកែសម្រួលបញ្ជីថ្លៃលក់អគ្គិសនីរបស់អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនតូច

ប្រសិនបើ អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនតូចស្នើសុំមកអាជ្ញាធរអគ្គិសនី កម្ពុជា ដើម្បី :

(ក) កែសម្រួលបញ្ជីថ្លៃលក់ទាំងមូល ឬក៏កែសម្រួលអត្រាថ្លៃ លក់អគ្គិសនីណាមួយ និង/ឬ

(ខ) កំណត់បញ្ជីថ្លៃលក់អគ្គិសនីថ្មី ឬកំណត់អត្រាថ្លៃលក់ថ្មី

អ្នកកាន់អាជ្ញាប័ណ្ណត្រូវផ្តល់ឱ្យអាជ្ញាធរអគ្គិសនីកម្ពុជានូវទិន្នន័យតាមគំរូ តារាង TS1 ដល់ TS13 នៃឧបសម្ព័ន្ធនេះ រួមទាំងពត៌មានផ្សេងៗទៀត ដែលអាជ្ញាធរអគ្គិសនីកម្ពុជាត្រូវការ។ ពត៌មាននៅក្នុងឧបសម្ព័ន្ធនេះ ទាក់ទងនឹងឆ្នាំការិយបរិច្ឆេទកំពុងអនុវត្ត ។

### ១- អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនតូច: ពត៌មានអំពីចំណាយត្រឹមត្រូវ

(i) អ្នកកាន់អាជ្ញាប័ណ្ណត្រូវផ្តល់នូវខ្លឹមសារលម្អិតអំពីចំណាយប្រេង ឥន្ធនៈ ចំណាយទិញថាមពល ចំណាយសម្រាប់ដំណើរការ និងការថែទាំ និងចំណាយរដ្ឋបាលនិងការគ្រប់គ្រងទូទៅ តាមគំរូតារាង TS1 រហូតដល់ TS5 នៃឧបសម្ព័ន្ធនេះ រួមជាមួយនឹងឯកសារយោងសមស្របផង ។

(ii) អ្នកកាន់អាជ្ញាប័ណ្ណត្រូវបង្ហាញនូវមូលធនជាក់ស្តែងផ្ទាល់របស់ខ្លួនតាមគំរូតារាង TS6 រហូតដល់TS8 នៃឧបសម្ព័ន្ធនេះ។

(iii) អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្តល់នូវការគណនាប្រាក់ចំណេញ សមស្រប តាមគំរូតារាង TS8 និងសេចក្តីសង្ខេបអំពី ចំណាយត្រឹមត្រូវតាមគំរូតារ TS10 ។

### ២- អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនតូច :ពត៌មានអំពីចំណាយត្រឹមត្រូវ

អ្នកកាន់អាជ្ញាប័ណ្ណត្រូវផ្តល់នូវពត៌មានលម្អិតអំពីចំណូលដែលទទួលបានពីថ្លៃលក់បច្ចុប្បន្ន និងថ្លៃលក់ស្នើសុំ សម្រាប់ឆ្នាំការិយបរិច្ឆេទបន្ទាប់ តាមគំរូតារាង TS11 ដល់ TS12 នៃឧបសម្ព័ន្ធនេះ ។ គំរូតារាង TS12 ផ្អែកលើរចនាសម្ព័ន្ធថ្លៃលក់ដែលស្នើសុំដោយអ្នកកាន់អាជ្ញាប័ណ្ណ ។

### ៣- អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនតូច: ពត៌មានអំពីថាមពល

តារាង TS13 មានពត៌មានលម្អិតអំពីថាមពលលក់ដែលប៉ាន់ស្មានដោយ អ្នកកាន់អាជ្ញាប័ណ្ណ និងថាមពលទិញ/ថាមពលផលិត ដែលគណនាដោយ ផ្អែកលើតួលេខបាត់បង់ដែលព្យាករណ៍ទុក ។